ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកំពង់ឆ្នាំង**

-សំណុំរឿងព្រហ្មទណ្ឌលេខ ៧២១
ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០២១។

-សាលក្រមព្រហ្មទណ្ឌលេខ ៩៩ (គ)
ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២៤។

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកំពង់ឆ្នាំង

បានបើកសវនាការជាសាធារណៈ នាថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៤ វេលាម៉ោង ៨,០០ ព្រឹក
ដែលមានសមាសភាពដូចខាងក្រោម ៖

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រម នៃសាលាដំបូងខេត្តកំពង់ឆ្នាំង

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពង់ឆ្នាំង

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៧២១ ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០២១ ដែលមានជនជាប់ចោទ ៖

-ឈ្មោះ [redacted]ប៊ុន ភេទប្រុស អាយុ ៤៩ ឆ្នាំ ជនជាតិខ្មែរ-សញ្ជាតិខ្មែរ មុខរបរ អាជីវករលក់ទិញត្រី ទីកន្លែងកំណើតគតនៅ [redacted] ខេត្ត កំពង់ស្ពឺ ,ទីលំនៅបច្ចុប្បន្ននៅភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង , ឪពុកឈ្មោះ [redacted]ហាំ (ស) ម្ដាយឈ្មោះ [redacted]គី (រ) ប្រពន្ធឈ្មោះ [redacted] សុ គន្ធា (រ) កូនចំនួន ០៤ នាក់ ទោសពីមុន គ្មាន អនីតិជន។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ: **ឈូសឆាយដីព្រៃលិចទឹក** ប្រព្រឹត្តនៅចំណុច ក្រោយទឹកស្អាត ស្ថិតនៅក្នុងភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូណ៌ ខេត្ត កំពង់ឆ្នាំង កាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោស តាមបញ្ញត្តិមាត្រា ៩៨ ចំណុច ១ នៃច្បាប់ស្ដីពីជលផល។

-មានលោក [redacted] ការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុន។

**ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ ៖**

-កាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១ នៅចំណុច ក្រោយទឹកស្អាត ស្ថិតនៅក្នុងភូមិ ផ្លុកទ្រូ ឃុំ



Scanned with CamScanner

ផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង មានអំពើ ៖ ឈូសឆាយដីព្រៃលិចទឹក ដែលប្រព្រឹត្តដោយឈ្មោះ [redacted] ប៊ុន បានលួចចូលទៅឈូសឆាយដីព្រៃលិចទឹកអស់ទំហំ ៤,៧២ ហិកតា នៅពេលយប់ បន្ទាប់មកក៏បានលួចចូលភ្ជួរដើម្បីសាបព្រួសស្រូវប្រាំង ក្នុងគោលបំណងបន្លំភ្នែកសមត្ថកិច្ចថា ជាដីធ្លាប់អាស្រ័យផលយូរឆ្នាំមកហើយ។ ក្រោយកំណត់មុខសញ្ញាបានហើយ សមត្ថកិច្ចជំនាញ ក៏បានកសាងសំណុំរឿងបញ្ជូនទៅអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ដើម្បីចាត់ការតាមនីតិវិធីបន្ត។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ប៊ុន បានឆ្លើយថា ខ្លួនសុំបដិសេធចំពោះការចោទប្រកាន់របស់តំណាងអយ្យការដែលបានចោទប្រកាន់ថា ខ្លួនបានឈូសឆាយដីព្រៃលិចទឹក នៅចំណុច ក្រោយទឹកស្អាត ស្ថិតនៅក្នុងភូមិ ផ្លុកទ្រូ ឃុំផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង កាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១។ ចំពោះថារឿងឈូសឆាយដីព្រៃលិចទឹក និងបានព្រោះស្រូវ ខ្លួនមិនបានប្រព្រឹត្តទេ ហើយការច្រូតយកផលស្រូវនោះ ក៏ខ្លួនមិនបានដឹងដែរ។នៅក្នុងរឿងហេតុនេះ ខ្លួនមិនបានចូលរួមដោះស្រាយអ្វីនោះទេ ចំពោះការប្ដឹងចោទប្រកាន់មកលើរូបខ្លួននេះ ខ្លួនបានសុំឱ្យតុលាការមេត្តាជួយរកយុត្តិធម៌ឱ្យរូបខ្លួនផង និងសុំឱ្យតុលាការលើកលែងការចោទប្រកាន់លើរូបខ្លួន ដោយហេតុថា ខ្លួនមិនបានប្រព្រឹត្តបទល្មើស ដូចការចោទប្រកាន់របស់តំណាងអយ្យការនោះឡើយ។ ខ្លួនមានសាក្សីដឹងឮ គឺឈ្មោះ [redacted] សារិន ភេទប្រុស អាយុ ៣៣ ឆ្នាំ រស់នៅភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង និងឈ្មោះ [redacted] ប៊ុនធឿន ភេទប្រុស អាយុ ៤៨ ឆ្នាំ រស់នៅភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង បញ្ជាក់ថា ខ្លួនមិនបានប្រព្រឹត្តអំពើនេះ។

-សាក្សីឈ្មោះ [redacted] សារិន បានឆ្លើយបំភ្លឺថា ខ្លួនជាកម្មកររបីសែងត្រីនៅមាត់កំពង់ទឹកនៅ ផ្លុកទ្រូ ខ្លួនមិនដែលឃើញឈ្មោះ [redacted] ប៊ុន នេះ ទៅឈូសឆាយដីព្រៃលិចទឹក នៅចំណុចក្រោយ ទឹកស្អាត ស្ថិតភូមិផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង នោះទេ ដឹងតែគាត់ជាអ្នករកស៊ីទិញ លក់ត្រីនៅមាត់កំពង់ផ្លុកទ្រូ រៀងរាល់ថ្ងៃ។ ខ្លួនស្គាល់ឈ្មោះ [redacted] ប៊ុន ជាអ្នករកស៊ីទិញលក់ត្រីនៅក្នុងភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង នេះយូរឆ្នាំមកហើយ។ ខ្លួនធ្លាប់បានធ្វើស្រែនៅលើដីព្រៃលិចទឹកនោះដែរ ដោយខ្លួនបានជួលត្រាក់ទ័រគេ ឱ្យភ្ជួរនៅពេលយប់ ហើយព្រឹកឡើងចាប់ផ្ដើមព្រោះស្រូវ តែមុននឹងធ្វើនេះ ខ្ញុំបាទបានទៅសុំលោកមេឃុំ ផ្លុកទ្រូ ឈ្មោះ សិន ហើយគាត់ក៏បានអនុញ្ញាតឱ្យខ្លួនធ្វើស្រែបានម្ដង។ នៅថ្ងៃខែមិនចាំ ឆ្នាំ ២០២១ ខ្លួនបានជួលម៉ាស៊ីនច្រូតស្រូវទៅច្រូតស្រូវនៅចំណុច ក្រោយទឹកស្អាត ស្ថិតនៅក្នុងភូមិ ផ្លុកទ្រូ នោះបានស្រូវប្រហែល ២០ ការ៉ុង ស្រាប់តែមានសមត្ថកិច្ចជលផលបានចុះមកហាមឃាត់ មិនអោយធ្វើស្រែនៅលើដីដែលរដ្ឋបានហាមឃាត់នេះទៀតទេ ,មានអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចជលផល បានចូលរួមដោះស្រាយនៅក្នុងរឿងឈូសឆាយដីព្រៃលិចទឹកនេះផងដែរ ហើយខ្លួនបានធ្វើកិច្ចសន្យានៅកន្លែងកើតហេតុជូនសមត្ថកិច្ចជលផល។ តាំងពីពេលនោះមក ខ្លួនបានប្រគល់ដីនោះ ជូនរដ្ឋវិញអស់ហើយ ហើយក៏មិនបានទៅបង្កបង្កើនផលអ្វីនៅលើដីនោះទៀតដែរ។ នៅពេលដែលសមត្ថកិច្ចមកដោះស្រាយនៅកន្លែងកើតហេតុ នៅក្នុងរឿងឈូស ឆាយដីព្រៃលិចទឹកនោះ ខ្លួនមិនបានឆ្លើយដាក់លើឈ្មោះ [redacted] ប៊ុន នេះទេ។ ហើយឈ្មោះ[redacted] ប៊ុន នេះ មិនដែលទៅចូលរួមក្នុងការដោះស្រាយរឿងឈូសឆាយដីព្រៃលិចទឹកជាមួយសមត្ថកិច្ចនោះឡើយ។

-សាក្សីឈ្មោះ [redacted] ប៊ុនធឿន បានឆ្លើយបំភ្លឺថា ខ្ញុំបាទជាអនុភូមិ ផ្លុកទ្រូ នៅក្នុងរឿងឈូសឆាយដីព្រៃលិចទឹក នៅចំណុច ក្រោយទឹកស្អាត ស្ថិតនៅភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំងនេះ



Scanned with CamScanner

ខ្លួនបានឃើញឈ្មោះ [redacted] សារិន យកស្រូវទៅព្រោះនៅលើដីរដ្ឋហាមឃាត់ ខ្លួនក៏សួរថា ឈ្មោះ [redacted] សារិន មិចបានជាយកស្រូវទៅព្រោះនៅលើដីដែលរដ្ឋហាមឃាត់អញ្ចឹង ឈ្មោះ [redacted] សារិន ឆ្លើយថា ឃើញដីនេះវាលស្រាប់។ នៅថ្ងៃកើតហេតុ ខ្លួនមិនចាំថ្ងៃ ខែ ទេ ក្នុងអំឡុងឆ្នាំ២០២១ ឈ្មោះ [redacted] សារិន បានមកច្រូតប្រមូលផលស្រូវ ស្រាប់តែមានសមត្ថកិច្ចជលផលបានចុះមកហាមឃាត់ មិនអោយធ្វើស្រែលើដីដែលរដ្ឋហាមឃាត់នោះទេ និងមានអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចជលផល បានចូលរួមដោះស្រាយនៅក្នុងរឿងឈូសឆាយដីព្រៃលិចទឹកនេះដែរ ហើយឈ្មោះ [redacted] សារិន បានធ្វើកិច្ចសន្យានៅកន្លែងកើតហេតុ ថាខ្លួនឈប់បង្កបង្កើនផលនៅតំបន់នេះទៀតហើយ ដីជូនសមត្ថកិច្ចជលផលវិញ។ ចាប់តាំងពីពេលនោះមកឈ្មោះ [redacted] សារិន បានប្រគល់ដីនោះជូនរដ្ឋវិញអស់ហើយ ហើយឈ្មោះ [redacted] សារិន មិនបានទៅបង្កបង្កើនផលលើដីនោះទៀតដែរ។ ខ្លួនមិនដែលឃើញឈ្មោះ [redacted] ប៊ុន នោះ ទៅឈូសឆាយដីព្រៃលិចទឹកនៅ ចំណុចភូមិ ផ្អកទ្រ ឃុំ ផ្អកទ្រ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង នោះទេ ដឹងតែគាត់ជាអ្នករកស៊ីទិញលក់ត្រី នៅមាត់កំពង់ផ្អកទ្រ រៀងរាល់ថ្ងៃ។នៅពេលដែលសមត្ថកិច្ចមកដោះស្រាយនៅកន្លែងកើតហេតុ នៅក្នុងរឿងឈូសឆាយដីព្រៃលិចទឹក នៅចំណុចក្រោយទឹកស្អាត ស្ថិតនៅក្នុងភូមិ ផ្អកទ្រ ឃុំ ផ្អកទ្រ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំងនេះ ខ្លួនបាននៅកន្លែងកើតហេតុនោះដែរ ខ្លួនមិនបានឃើញឈ្មោះ [redacted] ប៊ុន ចូលរួមដោះស្រាយនៅទីនេះទេ។

-លោក [redacted] សីហាក់ ជានាយផ្នែកជលផលផ្សារឆ្នាំង បានឆ្លើយបំភ្លឺថា នៅក្នុងរឿងឈូសឆាយដីព្រៃលិចទឹកនេះ ខ្លួនមិនបានចូលរួមទៅហាមឃាត់នោះទេ។ គឺលោកនាយសង្កាត់ជលផលបរិបូណ៍ ឈ្មោះ [redacted]បាន និងលោកនាយរងអធិការជលផលខាងត្បូងបឹងទន្លេសាប បានចូលរួមត្រួតពិនិត្យកន្លែងកើតហេតុផ្ទាល់ ដោយមូលហេតុថា ពួកគាត់ជាមន្ត្រីប្រចាំការនៅតំបន់នោះ ក្រោយពីឃើញហេតុការណ៍លួចឈូសឆាយដីព្រៃលិចទឹកនៅពេលយប់ និងសាបព្រោះស្រូវ លើដីទំហំប្រហែលជាង ០៤ ហិចតា នៅចំណុចក្រោយស្ថានីយ៍ផលិតទឹកស្អាត ស្ថិតក្នុងភូមិ ផ្អកទ្រ ឃុំ ផ្អកទ្រ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង។ ដោយក្នុងនោះ សមត្ថកិច្ចដែលប្រចាំការនៅតំបន់នោះ ពួកគាត់បានស្រាវជ្រាវរកជនល្មើស ដែលលួចឈូសឆាយដីព្រៃលិចទឹកនោះ ដែលមានរបាយការណ៍ថា ករណីនេះ ប្រព្រឹត្តឡើងដោយគ្រឿងចក្រ ០១ គ្រឿង មិនស្គាល់ឈ្មោះអ្នកបើក ហើយអ្នកដែលបានឱ្យជនមិនស្គាល់ឈ្មោះនោះចូលទៅឈូសឆាយដីនោះ គឺឈ្មោះ [redacted] ប៊ុន ជាអាជីវករទិញលក់ត្រី ដែលនៅជិតទីតាំងកន្លែងដែលមានការលួចឈូសឆាយដីព្រៃលិចទឹកនោះ។ ក្រោយពីដឹងខាងជំនាញបានកសាងសំណុំរឿងបញ្ជូនទៅតុលាការបាន ប្រហែលចន្លោះ ២ ទៅ ៣ ខែ រួចមក ក៏មានម៉ាស៊ីនច្រូតស្រូវ បើកបរដោយជនមិនស្គាល់ បានចូលទៅច្រូតស្រូវនៅទីតាំងដីព្រៃលិចទឹកដែលបានហាមឃាត់នោះ សមត្ថកិច្ចចម្រុះ រួមមាន សង្កាត់ជលផលបរិបូរណ៍ , នាយរងអធិការជលផលខាងត្បូងបឹងទន្លេសាប ,មន្ត្រីបរិស្ថាន ,មន្ត្រីកងរាជអាវុធស្រុក និងខេត្ត ដឹកនាំដោយលោក[redacted]សោភ័ណ្ឌ នាយរងខណ្ឌ បានធ្វើការឃាត់ម៉ាស៊ីនច្រូតស្រូវរួចមក ស្រាប់តែមានឈ្មោះ អាគរ ជាមេការរបស់ឈ្មោះ [redacted] ប៊ុន ,លោកមេឃុំ ផ្អកទ្រ និងលោកអភិបាលស្រុកបរិបូរណ៍ បានសម្របសម្រួលជាមួយប្រធានមន្ទីរកសិកម្ម ដោយអាជ្ញាធរមូលដ្ឋានសំណូមពរឱ្យលោកប្រធានមន្ទីរ កសិកម្មបញ្ចប់រឿង ដោយអោយឈ្មោះ អាគរ ជាមេការរបស់ឈ្មោះ [redacted] ប៊ុន យកម៉ាស៊ីនច្រូតស្រូវនោះចេញពីទីតាំងដីហាមឃាត់ ដែលទើបនឹងបានច្រូតស្រូវបានប្រមាណ ៣០% បានស្រូវប្រហែល ២០ ការ៉ុង ម៉ាស៊ីនច្រូតស្រូវដែលបានហាមឃាត់នោះ អាជ្ញាធរស្រុកបានឱ្យឈ្មោះ អាគរ ជាមេការរបស់ឈ្មោះ [redacted] ប៊ុន ប្រគល់ដីជូនរដ្ឋវិញដោយលែងប៉ះពាល់ទៀត។ នៅពេលដែលអាជ្ញាធររួមទាំងសមត្ថកិច្ចចម្រុះ បានធ្វើការដោះ



Scanned with CamScanner

ស្រាយ សម្របសម្រួលជាមួយឈ្មោះ អាគរ ជាមេការរបស់ឈ្មោះ [redacted] ប៊ុន ប្រគល់ដីជូនរដ្ឋវិញនោះ គឺស្ថិតក្នុងយុទ្ធនាការជុំវិញបឹងទន្លេ ដោយឱ្យប្រជាពលរដ្ឋដែលធ្វើកសិកម្ម និងកាន់កាប់ដីនៅតំបន់ ៣ ខុសច្បាប់ ត្រូវស្ម័គ្រចិត្តប្រគល់ដីជូនរដ្ឋវិញ។

-លោក [redacted] បាន ជានាយផ្នែកជលផលផ្សារឆ្នាំង បានឆ្លើយបំភ្លឺថា ខ្លួនសូមឆ្លើយបំភ្លឺថា នៅក្នុងរឿងឈូសឆាយដីព្រៃលិចទឹកនេះ ខ្លួនបានចូលរួមត្រួតពិនិត្យកន្លែងកើតហេតុផ្ទាល់ ឃើញថា មានស្លាកស្នាមឈូសឆាយដីព្រៃលិចទឹកនៅពេលយប់ នឹងព្រោះស្រូវ លើផ្ទៃដីចំនួនប្រហែលជាង ០៤ហិចតា នៅចំណុច ខាងកើតទឹកស្អាតផ្លូវលេខ ៥២ ស្ថិតក្នុងភូមិផ្អុកទ្រូ ឃុំ ផ្អុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង។ នៅពេលកើតហេតុនោះ ខ្លួនមិនបានឃើញជនល្មើសនោះទេ ព្រោះជនល្មើសបានធ្វើសកម្មភាពច្រើនតែនៅពេលយប់។ បន្ទាប់មក ខ្លួនបានធ្វើការស្រាវជ្រាវរកមុខសញ្ញាជនល្មើស ដែលលួចមកឈូសឆាយដីព្រៃលិចទឹកនោះ ស្រាប់តែក្នុងរយៈពេលដែលកំពុងតែស្រាវជ្រាវនោះ ស្រាប់តែលេចចេញឈ្មោះ [redacted] ប៊ុន បានមកជួបខ្លួន និងជួបលោក [redacted] ន តូ នាយរងអធិការខាងត្បូងបឹងទន្លេសាប បានមកស្នើសុំឱ្យបិទសំណុំរឿង កុំបញ្ជូនទៅតុលាការ នៅពេលនោះ ខ្លួនបានឱ្យឈ្មោះ [redacted] ប៊ុន ទៅជួបជាមួយលោកប្រធានមន្ទីរកសិកម្ម ព្រោះឯកសារខ្លួនបានបញ្ជូនទៅលោកប្រធានមន្ទីរកសិកម្មរួចហើយ។ នៅពេលដែលឈ្មោះ [redacted] ប៊ុន មកជួបខ្លួន និងនាយរងអធិការនោះ ខ្លួនមិនបានធ្វើលិខិតអ្វីនោះទេ គឺជួបនិយាយដោយផ្ទាល់មាត់ ហើយឈ្មោះ [redacted] ប៊ុន បានសុំធ្វើស្រែបន្តទៀត នៅលើដីដែលបានហាមឃាត់នោះ និងមិនបាននិយាយអ្វីប៉ះពាល់ទៅលើឈ្មោះ [redacted] សារិន ហៅ គរ នោះទេ តែជាក់ស្តែង គឺឈ្មោះ [redacted] សារិន ហៅ គរ នេះបានច្រូតស្រូវនៅលើដីខាងលើដែរ។ លុះក្រោយមកខ្លួន និងនាយរងអធិការ បានមកឆ្លងយោបល់លោកប្រធានមន្ទីរ តែលោកប្រធានមន្ទីរបានប្រាប់ថា មិនអាចបិទសំណុំរឿងបាននោះទេ ព្រោះរឿងនេះ បានបញ្ជូនមកតុលាការហើយ។ លុះបានរយៈពេលប្រហែល ១ ខែ ទៅ ២ ខែស្រាប់តែឈ្មោះ [redacted] សារិន ហៅ គរ ជាមេការរបស់ឈ្មោះ [redacted] ប៊ុន បានយកម៉ាស៊ីនច្រូតស្រូវមកច្រូតស្រូវ បានប្រមាណ៣០% បានប្រហែល ១០ ការ៉ុង ទើបសមត្ថកិច្ចចម្រុះមាន កងរាជអាវុធហត្ថ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចជលផល បានចុះមកដល់កន្លែងកើតហេតុ ដោយឱ្យឈ្មោះ [redacted] សារិន ហៅ គរ បញ្ឈប់ធ្វើ សកម្មភាពច្រូតស្រូវនៅលើដីតំបន់៣ ដែលរដ្ឋហាមឃាត់។ បន្ទាប់មកខាងជំនាញជលផលបានធ្វើ កំណត់ហេតុស្តីពីការចុះពិនិត្យនិងស្រាវជ្រាវការកាប់បំផ្លាញព្រៃលិចទឹក នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០២១ ដោយមានឈ្មោះ [redacted] សារិន ហៅ គរ បានផ្តិតមេដៃនៅលើកំណត់ហេតុផងដែរ។ នៅពេលសាកសួរនោះ ឈ្មោះ [redacted] សារិន ហៅ គរ មិនបានឆ្លើយដាក់លើ ឈ្មោះ [redacted] ប៊ុន នោះទេ។ លុះបានរយៈពេលប្រហែលកន្លះខែ ស្រាប់តែឈ្មោះ [redacted] ប៊ុន និងប្រពន្ធ បានពឹងខ្ញុំបាទឱ្យជួយជូនមកជួបលោកប្រធានមន្ទីរកសិកម្ម ដើម្បីស្នើសុំធ្វើស្រែបន្តទៀត តែលោក ប្រធានមន្ទីរបានបដិសេធមិនអនុញ្ញាតឱ្យធ្វើស្រែនោះទេ។

-លោក [redacted] តូ ជានាយរងអធិការខាងត្បូងបឹងទន្លេសាប បានឆ្លើយបំភ្លឺថា នៅក្នុងរឿងឈូសឆាយដីព្រៃលិចទឹកនេះ ខ្លួនបានចូលរួមត្រួតពិនិត្យកន្លែងកើតហេតុផ្ទាល់ ឃើញថា មានស្លាកស្នាមឈូស ឆាយដីព្រៃលិចទឹកនៅពេលយប់ លើផ្ទៃដីចំនួនប្រហែល ០៤ ហិចតា ៧២ អា នៅចំណុចខាងកើតទឹកស្អាត ផ្លូវលេខ ៥២ ស្ថិតនៅក្នុងភូមិ ផ្អុកទ្រូ ឃុំ ផ្អុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង។ នៅពេលកើតហេតុនោះ មិនបានឃើញជនល្មើសនោះទេ ព្រោះជនល្មើសបានធ្វើសកម្មភាពនៅពេលយប់។ បន្ទាប់មក ខ្លួនបានធ្វើការស្រាវជ្រាវរកមុខសញ្ញានៃជនល្មើស ដែលលួចមកឈូសឆាយដីព្រៃលិចទឹកនោះ ស្រាប់តែក្នុងរយៈពេលដែលកំពុងស្រាវ



Scanned with CamScanner

ជ្រាវនោះ បានប្រហែល ០៣ ថ្ងៃ ស្រាប់តែឈ្មោះ [redacted] ប៊ុន បានតេទូរស័ព្ទទំនាក់ទងតាមលេខរបស់គាត់ ០១២ ៧១០ ៦៧៧ មកខ្លួនតាមរយៈលេខទូរស័ព្ទ ០១២ ៣៧ ០០ ១៤ បានស្នើសុំឱ្យខ្លួនជួយអន្តរាគមន៍មកប្រធានមន្ទីរកសិកម្ម ដើម្បីបញ្ឈប់កុំឱ្យបញ្ជូនសំណុំរឿងទៅសាលាដំបូងខេត្តកំពង់ឆ្នាំង។ ពេលនោះ ខ្លួនបានផ្លងយោបល់លោកប្រធានមន្ទីរកសិកម្ម ហើយលោកប្រធានមន្ទីរបានប្រាប់ថា មិនអាចបញ្ឈប់បានទេ ត្រូវតែបញ្ជូនទៅតុលាការ ព្រោះរឿងនេះ ដឹងដល់រដ្ឋមន្ត្រីក្រសួងកសិកម្មហើយ។ នៅពេលដែលឈ្មោះ [redacted] ប៊ុន មកជួបខ្លួននោះមិនបានធ្វើកំណត់ហេតុនោះទេ ព្រោះជួបនិយាយដោយផ្ទាល់មាត់។ លុះបានរយៈពេលប្រហែល ៣ ខែ ស្រាប់តែឈ្មោះ [redacted] សារិន ហៅ គរ ជាមេការរបស់ឈ្មោះ [redacted] ប៊ុន បានយកម៉ាស៊ីនច្រូតស្រូវមកច្រូតស្រូវបានប្រមាណ ៣០% ទៅ ៤០% តែខ្លួនមិនបានចុះទៅកន្លែងកើតហេតុនោះទេ គឺទទួលដំណឹងពីប្រជាជនរស់នៅទីនោះ។ ក្រោយមក ខ្លួនបានប្រាប់ទៅប្រធានមន្ទីរ ហើយប្រធានមន្ទីរបានទំនាក់ទំនងទៅលោកនាយសង្កាត់ ទើបមានសមត្ថកិច្ចចម្រុះ ,កងរាជអាវុធហត្ថ ,អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចជលផល បានចុះមកដល់កន្លែងកើតហេតុ ដោយឱ្យឈ្មោះ [redacted] សារិន ហៅ គរ បញ្ឈប់ធ្វើសកម្មភាពច្រូតស្រូវនៅលើដីតំបន់ ៣ ដែលរដ្ឋហាមឃាត់។ ឈ្មោះ [redacted] សារិន ហៅ គរ ជាតែកុងឡានដឹកត្រីឱ្យឈ្មោះ [redacted] ប៊ុន រហូតដល់សព្វថ្ងៃនេះឈ្មោះ [redacted] សារិន ហៅ គរ ក៏មិនមានដី និងផ្ទះនៅក្នុងភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង នោះដែរ។

-អំណានកំណត់ហេតុ ចុះពិនិត្យកន្លែងកើតហេតុ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១ របស់មន្ត្រីជលផល មានខ្លឹមសារ មានស្នាមឈូសឆាយដីព្រៃលិចទឹក ០១ កន្លែង ដោយគ្រាក់ទ័រនៅពេលយប់ និងព្រោះស្រូវបន្ថែមនៅលើដីដែលបានឈូសឆាយដី ក្នុងហេតុផលថា ធ្លាប់បង្កបង្កើនផលចាស់ នៅក្នុងដីព្រៃលិចទឹកដែលត្រូវការពារ។ ដីដែលបានឈូសឆាយមានទំហំប្រមាណ ៤,៧៨១ ហិចតា ហើយជនល្មើសមិនបាននៅកន្លែងកើតហេតុទេ។

-តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថា៖ឆ្លងតាមការសួរដេញដោលនៅពេលសវនាការ និងពិនិត្យឯកសារផ្សេងៗក្នុងសំណុំរឿង កាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១ មានការឈូសឆាយដីព្រៃលិចទឹក ដើមឡើយជំនាញជលផលបានធ្វើសេចក្តីសន្និដ្ឋានតាមរបាយការណ៍សរុបលេខ ០៦ ជផ.កឆ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ តាមការស្រាវជ្រាវរបស់ខ្លួនអ្នកដែលបានប្រព្រឹត្តក្នុងរឿងនេះ មានឈ្មោះ [redacted] ប៊ុន បានឈូសឆាយដីព្រៃលិចអស់ទំហំ ៤ ហិចតា ៧២ អា នៅពេលយប់ ក្រោយមកនៅថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០២១ តាមការបញ្ជាក់របស់ជំនាញថាមានអ្នកទៅទទួល ដែលមានឈ្មោះ [redacted] សារិន ហៅ គរ។ ជាក់ស្តែងមកដល់ពេលនេះឈ្មោះ [redacted] សារិន ហៅ គរ បានឆ្លើយសារភាពថា ខ្លួនជាអ្នកទៅទទួលផល និងបានធ្វើសកម្មភាពកាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១ ការដែលខ្លួនទៅទទួលផលនោះ គឺមិនមានការបញ្ជាពីឈ្មោះ [redacted] ប៊ុន ឬធ្វើការក្នុងនាមឈ្មោះ [redacted] ប៊ុន ដែលជាថៅកែ ឬជាកម្មករដឹកត្រីឱ្យគាត់ទេ អ្វីដែលរបាយការណ៍សរុបរបស់ជលផលបញ្ជូនមកដាក់ថាឈ្មោះ [redacted] ប៊ុន ជាអ្នកប្រព្រឹត្ត មិនជាប់ពាក់ព័ន្ធអ្នកផ្សេងទៀត ដាក់តាមការស្រាវជ្រាវ។ ពេលសួរនាំពីការស្រាវជ្រាវថា ពាក់ព័ន្ធទៅនឹងទូរស័ព្ទថា ឈ្មោះ [redacted] ប៊ុន បានស្នើសុំឱ្យមន្ត្រីជំនាញបិទសំណុំរឿង អ្នកជំនាញបញ្ជាក់ថា ការឱ្យជួយបិទនេះ ដើម្បីអ្នកប្រព្រឹត្ត ឬអ្នកដទៃមិនសំខាន់ទេ ឈ្មោះ [redacted] ប៊ុន ខ្លួនឯងឮថាជំនាញជលផលបានកសាងសំណុំរឿងថា ខ្លួនជាអ្នកប្រព្រឹត្តបានសុំជួបមន្ត្រីជំនាញទាំងអស់នោះ តាមរយៈទូរស័ព្ទផង អ្នកខ្លះក៏ជួបផ្ទាល់ផង សុំឱ្យមន្ទីរកសិកម្មជួយបិទ កុំឱ្យធ្វើការបញ្ជូន តែទីបំផុតរឿងនេះ ត្រូវបាន



Scanned with CamScanner

បញ្ជូនមកតែឈ្មោះ [redacted] ប៊ុន ដោយឡែកឈ្មោះ [redacted] សារិន ហៅ គរ ដែលជាអ្នកទទួលផលនៅក្នុងថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០២១ អត់បានកសាងសំណុំរឿងនោះមកទេ អញ្ចឹងទេមានន័យថា អ្នកដែលបានប្រព្រឹត្ត យើងរកឃើញហើយកាលពីថ្ងៃនោះ ទីបំផុតអត់ធ្វើសំណុំរឿងមក បានធ្វើសំណុំរឿងលេងៗ ឡេវល សំអាងតាមរយៈទូរស័ព្ទ ហើយសន្និដ្ឋានតែម្តងថា អ្នកណឹងគឺជាអ្នកប្រព្រឹត្ត អ្នកណឹងជាអ្នកពាក់ព័ន្ធ និងជាអ្នកធ្វើសកម្មភាពកាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១។ បើយើងបូកសរុបលទ្ធផលជុំវិញសវនាការដេញដោល ឃើញថាឈ្មោះ [redacted] ប៊ុន ហាក់ដូចជាពុំមានសញ្ញាញដែលបញ្ជាក់ថា ជាអ្នកប្រព្រឹត្តក្នុងរឿងនេះទេ ដោយសារតែចម្លើយមន្ត្រីជំនាញថា ឈ្មោះ [redacted] ប៊ុន សុំឱ្យគាត់ជួយបិទសំណុំរឿង និងសុំបង្កបង្កើនផលនៅលើនោះដើម្បីខ្លួនគាត់ផ្ទាល់ ឬដើម្បីអ្នកដទៃ។ ខ្ញុំសូមឱ្យចៅក្រមជំនុំជម្រះពិចារណាលើឈ្មោះ [redacted] ប៊ុន ដែលបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះពីបទ៖ ឈូសឆាយដីព្រៃលិចទឹក ប្រព្រឹត្តនៅចំណុចទឹកស្អាត ស្ថិតនៅភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុកបរិបូណ៌ ខេត្ត កំពង់ឆ្នាំង កាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១ និងសូមឱ្យជំនាញយោងតាមមាត្រា ១០ និយាយពីអាយុកាលបទល្មើសគិតថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១ ដល់ថ្ងៃសវនាការ បានបញ្ជាក់ថា មិនទាន់បានកសាងសំណុំរឿង ទីតាំងអ្នកប្រព្រឹត្តបានសារភាពសូមធ្វើសំណុំរឿងទាំងអស់មកតាមក្រោយ ដោយរៀបរាប់អំពីអង្គហេតុ និងអំពើ ដើម្បីបានជាលទ្ធផលថា អ្នកណាទទួលខុសត្រូវ និងអ្នកណាជាអ្នកប្រព្រឹត្ត បើអញ្ចឹងទេ ទីតាំងណឹងមួយត្រូវបាត់អ្នកទទួលខុសត្រូវ និងអ្នកប្រព្រឹត្តបទល្មើសគ្រាន់តែគិតថា បានប្រគល់ដីនេះ ឱ្យរដ្ឋវិញរួចខ្លួន អញ្ចឹងទេ នឹងមានប្រជាពលរដ្ឋ និងអ្នកប្រព្រឹត្តបទផ្សេងៗទៀតរួចខ្លួនទាំងអស់ គ្រាន់តែប្រគល់ដីឱ្យរដ្ឋវិញនោះ អញ្ចឹងគ្មានអ្នកណាខ្លាច និងគោរពច្បាប់ទេ អញ្ចឹងខ្ញុំសូមណែនាំទៅមន្ត្រីជំនាញ ឱ្យកសាងសំណុំរឿងនេះឡើងវិញ ដែលមានអង្គហេតុ កាលពី ០៥ ខែ សីហា ឆ្នាំ ២០២១ និងថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០២១។ ដោយឡែកអង្គហេតុដែលបានចោទប្រកាន់លើឈ្មោះ [redacted] ប៊ុន ដែលមានវត្តមានមកនេះ ខ្ញុំសូមឱ្យចៅក្រមពិនិត្យពិណា ថាតើគាត់បានប្រព្រឹត្ត ឬមិនបានប្រព្រឹត្តបើតាមជំនាញ មិនបានបញ្ជាក់ថា បានប្រព្រឹត្តតែមិនបានសារភាពហើយ ក៏គ្មានភស្តុតាងណាដាក់បន្ទុកថាឈ្មោះ [redacted] ប៊ុន ជាអ្នកធ្វើសកម្មភាពនៅថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១។ សូមឱ្យតុលាការសម្រេចតាមច្បាប់។

-លោក [redacted] មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុន បានធ្វើសេចក្តីសន្និដ្ឋានការពារថា ខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុន ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៧២១ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ខ្ញុំបាទសូមធ្វើសេចក្តីសន្និដ្ឋានដើម្បីការពារសិទ្ធិឱ្យកូនក្តីខ្ញុំបាទដូចតទៅ៖ ឆ្លងតាមការពិភាក្សាសួរដេញដោល និងសាកសួរនូវសំនួរ បានឱ្យឃើញថា ចម្លើយរបស់ខាងមន្ត្រីជលផលហាក់បីដូចជាមានការច្រពិចច្រពិល ពុំអាចជាភស្តុតាងដាក់បន្ទុកមកលើកូនក្តីខ្លួន ពីបទ: ឈូសឆាយដីព្រៃលិចទឹក បានទេ។ ជាក់ស្តែងកាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១ ពិតជាមានការឈូសឆាយដីព្រៃលិចទឹកពិតមែន ប៉ុន្តែ រកពុំឃើញជនល្មើសណាមួយទៅប្រព្រឹត្តពិតប្រាកដនោះឡើយ។ ហើយខាងជំនាញជលផលដែលបានទទួលដំណឹងថា កូនក្តីខ្លួនបានប្រព្រឹត្តបទល្មើសនេះ គាត់គ្រាន់តែបានទទួលទូរស័ព្ទពីកូនក្តីខ្លួនថា សុំបិទសំណុំរឿង ប៉ុន្តែមិនដឹងសំណុំរឿងខ្លួនឯង ឬអ្នកដទៃនោះទេ គ្រាន់តែទទួលបានការស្នើសុំនេះ គាត់ធ្វើការសន្និដ្ឋានថា អ្នកប្រព្រឹត្តនេះ ជាកូនក្តីរបស់ខ្ញុំបាទឈ្មោះ [redacted] ប៊ុន។ការដែលកូនក្តីខ្ញុំបាទសួរនាំទៅខាងមន្ត្រីជំនាញជលផលនោះ ព្រោះមានការភ័យខ្លាច ដោយសារគាត់មិនមានរឿងអ្វីសោះ បែរជាមានការចោទប្រកាន់ទៅលើរូបគាត់ និងបញ្ជូនសំណុំរឿងទៅតុលាការ ដោយចោទថា គាត់ជាអ្នកឈូសឆាយដីព្រៃ



Scanned with CamScanner

លិចទឹកនេះ។ ក្នុងរឿងនេះ សាក្សីឈ្មោះ [redacted] សារិន គាត់បានសារភាពថា គាត់ជាអ្នកប្រព្រឹត្ត អំពើឈូសឆាយដីព្រៃលិចទឹកនេះ កាលថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១ នោះ ហើយគាត់ក៏បានទៅប្រមូលផលនៅលើដីនោះផងដែរ ហើយក៏បានបញ្ជាក់ថា គាត់មិនបានទៅបង្កបង្កើន និងប្រមូលផលស្រូវ យកទៅឱ្យកូនក្ដីរបស់ខ្លួនឡើយ។ យ៉ាងទៀតកូនក្ដីខ្លួនជាអ្នកមានមុខរបររកស៊ី ទិញលក់ត្រី គាត់តែងតែមានទំនាក់ទំនងខាងមន្ត្រីជលផល តែការទាក់ទងរបស់គាត់ហាក់បីមានការប៉ះទង្គិចជាមួយសមត្ថកិច្ចមួយចំនួន ដូចនេះ អាចថា មកពីគំនុំអ្វីមួយ ក៏អាចថាបានដែរ ពាក់ព័ន្ធចំណុចវិវាទ គឺអត់មានភស្តុតាង ឬឯកសារណា ដែលបញ្ជាក់ថា កូនក្ដីខ្លួន បានពាក់ព័ន្ធទៅនឹងការឈូសឆាយដីព្រៃលិចទឹកនោះឡើយទាក់ទងនឹងការបំភ្លឺរបស់មន្ត្រីជលផលនោះគឺ គាត់សំដៅទៅលើតែឈ្មោះ [redacted] សារិន ម្នាក់តែប៉ុណ្ណោះ ពុំពាក់ព័ន្ធជាមួយកូនក្ដីរបស់ខ្ញុំបាទឡើយ ហេតុដូច្នេះហើយ ក្នុងរឿងនេះ គឺពុំមានភស្តុតាងដាក់បន្ទុក ធាតុផ្សំបទល្មើសគ្រាប់គ្រាន់មកលើកូនក្ដីខ្ញុំបាទឈ្មោះ[redacted] ប៊ុន ពីបទ៖ ឈូសឆាយដីព្រៃលិចទឹកនោះទេ។ សំណូមពរ សូមលោកចៅក្រមមេត្តាសម្រេចឱ្យឈ្មោះ[redacted] ប៊ុន រួចផុតពីបទចោទប្រកាន់។

-ជនជាប់ចោទឈ្មោះ [redacted] ប៊ុន បាននិយាយសំដីចុងក្រោយថាសុំឱ្យតុលាការសម្រេចបញ្ចប់សំណុំរឿងនេះ។

-ក្រោយពីបានស្ដាប់ចម្លើយ របស់ជនជាប់ចោទ។

-ក្រោយពីបានស្ដាប់ចម្លើយបំភ្លឺរបស់សាក្សី។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានប្ដឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ។

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់រួចហើយ។

**សាលាដំបូងខេត្តកំពង់ឆ្នាំងយល់ឃើញថា៖**

១-ជនជាប់ចោទឈ្មោះ [redacted] ប៊ុន ភេទប្រុស អាយុ ៤៩ ឆ្នាំ ជនជាតិខ្មែរ-សញ្ជាតិខ្មែរ ត្រូវបានចៅក្រមស៊ើបសួរបញ្ជូនមកជំនុំជម្រះពីបទៈ **ឈូសឆាយដីព្រៃលិចទឹក** ប្រព្រឹត្តនៅចំណុច ក្រោយទឹកស្អាត ស្ថិតនៅក្នុងភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូណ៌ ខេត្ត កំពង់ឆ្នាំង កាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោស តាមបញ្ញត្តិមាត្រា ៩៨ ចំណុច ១ នៃច្បាប់ស្ដីពីជលផល។

២-ជនជាប់ចោទឈ្មោះ [redacted] ប៊ុន បានឆ្លើយថា ខ្លួនសុំបដិសេធចំពោះការចោទប្រកាន់របស់តំណាងអយ្យការដែលបានចោទប្រកាន់ថា ខ្លួនបានឈូសឆាយដីព្រៃលិចទឹក នៅចំណុច ក្រោយទឹកស្អាត ស្ថិតនៅក្នុងភូមិផ្លុកទ្រូ ឃុំផ្លុ កទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង កាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១។ចំពោះថារឿងឈូសឆាយដីព្រៃលិចទឹក និងបានព្រោះស្រូវ ខ្លួនមិនបានប្រព្រឹត្តទេ ហើយការច្រូតយកផលស្រូវនោះ ក៏ខ្លួនមិនបានដឹងដែរ។នៅក្នុងរឿងហេតុនេះ ខ្លួនមិនបានចូលរួមដោះស្រាយអ្វីនោះទេ ចំពោះការប្ដឹងចោទប្រកាន់មកលើរូបខ្លួននេះ ខ្លួនបានសុំឱ្យតុលាការមេត្តាជួយរកយុត្តិធម៌ឱ្យរូបខ្លួនផង និងសុំឱ្យតុលាការលើកលែងការចោទប្រកាន់លើរូបខ្លួន ដោយហេតុថា ខ្លួនមិនបានប្រព្រឹត្តបទល្មើស ដូចការចោទប្រកាន់របស់តំណាងអយ្យការនោះឡើយ។ ខ្លួនមានសាក្សីដឹងឮ គឺឈ្មោះ [redacted] សារិន ភេទប្រុស អាយុ ៣៣ ឆ្នាំ រស់នៅភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង និងឈ្មោះ ចន ប៊ុនធឿន ភេទប្រុស អាយុ ៤៨ ឆ្នាំ រស់នៅភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង បញ្ជាក់ថា ខ្លួនមិនបានប្រព្រឹត្តអំពើនេះ។ ចម្លើយនេះ គប្បី



Scanned with CamScanner

គុណាការពិចារណា។

៣-សាក្សីឈ្មោះ [redacted] សារិន បានឆ្លើយបំភ្លឺថា ខ្លួនជាកម្មកររលីសែងត្រីនៅមាត់កំពង់ទឹកនៅ ផ្លុកទ្រូ ខ្លួនមិនដែលឃើញឈ្មោះ [redacted] ប៊ុន នេះ ទៅឈ្ូសឆាយដីព្រៃលិចទឹក នៅចំណុចក្រោយ ទឹកស្អាត ស្ថិតភូមិផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង នោះទេ ដឹងតែគាត់ជាអ្នករកស៊ីទិញ លក់ត្រីនៅមាត់កំពង់ផ្លុកទ្រូ រៀងរាល់ថ្ងៃ។ ខ្លួនស្គាល់ឈ្មោះ [redacted] ប៊ុន ជាអ្នករកស៊ីទិញលក់ត្រីនៅក្នុងភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង នេះយូរឆ្នាំមកហើយ។ ខ្លួនធ្លាប់បានធ្វើស្រែនៅលើដីព្រៃលិចទឹកនោះដែរ ដោយខ្លួនបានជួលត្រាក់ទ័រគេ ឱ្យភ្ជួរនៅពេលយប់ ហើយព្រឹកឡើងចាប់ផ្តើមព្រោះស្រូវ តែមុននឹងធ្វើនេះ ខ្ញុំបាទបានទៅសុំលោកមេឃុំ ផ្លុកទ្រូ ឈ្មោះ សិន ហើយគាត់ក៏បានអនុញ្ញាតឱ្យខ្លួនធ្វើស្រែបានម្តង។ នៅថ្ងៃខែមិនចាំ ឆ្នាំ ២០២១ ខ្លួនបានជួលម៉ាស៊ីនច្រូតស្រូវទៅច្រូតស្រូវនៅចំណុច ក្រោយទឹកស្អាត ស្ថិតនៅក្នុងភូមិ ផ្លុកទ្រូ នោះ បានស្រូវប្រហែល ២០ ការ៉ុង ស្រាប់តែមានសមត្ថកិច្ចជលផលបានចុះមកហាមឃាត់ មិនអោយធ្វើស្រែនៅលើដីដែលរដ្ឋបានហាមឃាត់នេះទៀតទេ ,មានអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចជលផល បានចូលរួមដោះស្រាយនៅក្នុងរឿងឈ្ូសឆាយដីព្រៃលិចទឹកនេះផងដែរ ហើយខ្លួនបានធ្វើកិច្ចសន្យានៅកន្លែងកើតហេតុជូនសមត្ថកិច្ចជលផល។ តាំងពីពេលនោះមក ខ្លួនបានប្រគល់ដីនោះ ជូនរដ្ឋវិញអស់ហើយ ហើយក៏មិនបានទៅបង្កបង្កើនផលអ្វីនៅលើដីនោះទៀតដែរ។ នៅពេលដែលសមត្ថកិច្ចមកដោះស្រាយនៅកន្លែងកើតហេតុ នៅក្នុងរឿងឈ្ូស ឆាយដីព្រៃលិចទឹកនោះ ខ្លួនមិនបានឆ្លើយដាក់លើឈ្មោះ [redacted] ប៊ុន នេះទេ។ ហើយឈ្មោះ [redacted] ប៊ុន នេះ មិនដែលទៅចូលរួមក្នុងការដោះស្រាយរឿងឈ្ូសឆាយដីព្រៃលិចទឹកជាមួយសមត្ថកិច្ចនោះឡើយ។ ចម្លើយនេះ គប្បីតុលាការពិចារណា។

៤-សាក្សីឈ្មោះ [redacted] ប៊ុនធឿន បានឆ្លើយបំភ្លឺថា ខ្ញុំបាទជាអនុភូមិ ផ្លុកទ្រូ នៅក្នុងរឿងឈ្ូសឆាយដីព្រៃលិចទឹក នៅចំណុច ក្រោយទឹកស្អាត ស្ថិតនៅភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំងនេះ ខ្លួនបានឃើញឈ្មោះ [redacted] សារិន យកស្រូវទៅព្រោះនៅលើដីរដ្ឋហាមឃាត់ ខ្លួនក៏សួរថា ឈ្មោះ [redacted] សារិន មិចបានជាយកស្រូវទៅព្រោះនៅលើដីដែលរដ្ឋហាមឃាតអញ្ចឹង ឈ្មោះ [redacted] សារិន ឆ្លើយថា ឃើញដីនេះវាលស្រាប់។ នៅថ្ងៃកើតហេតុ ខ្លួនមិនចាំថ្ងៃ ខែ ទេ ក្នុងអំឡុងឆ្នាំ២០២១ ឈ្មោះ [redacted] សារិន បានមកច្រូតប្រមូលផលស្រូវ ស្រាប់តែមានសមត្ថកិច្ចជលផលបានចុះមកហាមឃាត់ មិនអោយធ្វើស្រែលើដីដែលរដ្ឋហាមឃាត់នោះទេ និងមានអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចជលផល បានចូលរួមដោះស្រាយនៅក្នុងរឿងឈ្ូសឆាយដីព្រៃលិចទឹកនេះដែរ ហើយឈ្មោះ [redacted] សារិន បានធ្វើកិច្ចសន្យានៅកន្លែងកើតហេតុ ថាខ្លួនឈប់បង្កបង្កើនផលនៅតំបន់នេះទៀតហើយ ដីជូនសមត្ថកិច្ចជលផលវិញ។ ចាប់តាំងពីពេលនោះមកឈ្មោះ [redacted] សារិន បានប្រគល់ដីនោះជូនរដ្ឋវិញអស់ហើយ ហើយឈ្មោះ [redacted] សារិន មិនបានទៅបង្កបង្កើនផលលើដីនោះទៀតដែរ។ ខ្លួនមិនដែលឃើញឈ្មោះ [redacted] ប៊ុន នោះ ទៅឈ្ូសឆាយដីព្រៃលិចទឹកនៅ ចំណុចភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង នោះទេ ដឹងតែគាត់ជាអ្នករកស៊ីទិញលក់ត្រី នៅមាត់កំពង់ផ្លុកទ្រូ រៀងរាល់ថ្ងៃ។នៅពេលដែលសមត្ថកិច្ចមកដោះស្រាយនៅកន្លែងកើតហេតុ នៅក្នុងរឿងឈ្ូសឆាយដីព្រៃលិចទឹក នៅចំណុចក្រោយទឹកស្អាត ស្ថិតនៅក្នុងភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំងនេះ ខ្លួនបាននៅកន្លែងកើតហេតុនោះដែរ ខ្លួនមិនបានឃើញឈ្មោះ [redacted] ប៊ុន ចូលរួមដោះស្រាយនៅទីនេះទេ។ ចម្លើយនេះ គប្បីតុលាការពិចារណា។



Scanned with CamScanner

៥-លោក [redacted] សីហាក់ ជានាយផ្នែកជលផលផ្សារឆ្នាំង បានឆ្លើយបំភ្លឺថា នៅក្នុងរឿងឈូសឆាយដីព្រៃលិចទឹកនេះ ខ្លួនមិនបានចូលរួមទៅហាមឃាត់នោះទេ។ គឺលោកនាយសង្កាត់ជលផលបរិបូណ៌ ឈ្មោះ [redacted] បាន និងលោកនាយរងអធិការជលផលខាងត្បូងបឹងទន្លេសាប បានចូលរួមត្រួតពិនិត្យកន្លែងកើតហេតុផ្ទាល់ ដោយមូលហេតុថា ពួកគាត់ជាមន្ត្រីប្រចាំការនៅតំបន់នោះ ក្រោយពីឃើញហេតុការណ៍លួចឈូសឆាយដីព្រៃលិចទឹកនៅពេលយប់ និងសាបព្រោះស្រូវ លើដីទំហំប្រហែលជាង ០៤ ហិចតា នៅចំណុចក្រោយស្ថានីយ៍ផលិតទឹកស្អាត ស្ថិតក្នុងភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង។ ដោយក្នុងនោះ សមត្ថកិច្ចដែលប្រចាំការនៅតំបន់នោះ ពួកគាត់បានស្រាវជ្រាវរកជនល្មើស ដែលលួចឈូសឆាយដីព្រៃលិចទឹកនោះ ដែលមានរបាយការណ៍ថា ករណីនេះ ប្រព្រឹត្តឡើងដោយគ្រឿងចក្រ ០១ គ្រឿង មិនស្គាល់ឈ្មោះអ្នកបើក ហើយអ្នកដែលបានឱ្យជនមិនស្គាល់ឈ្មោះនោះចូលទៅឈូសឆាយដីនោះ គឺឈ្មោះ [redacted] ប៊ុន ជាអាជីវករទិញលក់ត្រី ដែលនៅជិតទីតាំងកន្លែងដែលមានការលួចឈូសឆាយដីព្រៃលិចទឹកនោះ។ ក្រោយពីដឹងខាងជំនាញបានកសាងសំណុំរឿងបញ្ជូនទៅតុលាការបាន ប្រហែលចន្លោះ ២ ទៅ ៣ ខែ រួចមក ក៏មានម៉ាស៊ីនច្រូតស្រូវ បើកបរដោយជនមិនស្គាល់ បានចូលទៅច្រូតស្រូវនៅទីតាំងដីព្រៃលិចទឹកដែលបានហាមឃាត់នោះ សមត្ថកិច្ចចម្រុះរួមមាន សង្កាត់ជលផលបរិបូរណ៍ , នាយរងអធិការជលផលខាងត្បូងបឹងទន្លេសាប ,មន្ត្រីបរិស្ថាន ,មន្ត្រីកងរាជអាវុធស្រុក និងខេត្ត ដឹកនាំដោយលោក [redacted] សោភ័ណ្ឌ នាយរងខណ្ឌ បានធ្វើការឃាត់ម៉ាស៊ីនច្រូតស្រូវរួចមក ស្រាប់តែមានឈ្មោះ អាគរ ជាមេការរបស់ឈ្មោះ [redacted] ប៊ុន ,លោកមេឃុំ ផ្លុកទ្រូ និងលោកអភិបាលស្រុកបរិបូរណ៍ បានសម្របសម្រួលជាមួយប្រធានមន្ទីរកសិកម្ម ដោយអាជ្ញាធរមូលដ្ឋានសំណូមពរឱ្យលោកប្រធានមន្ទីរ កសិកម្មបញ្ចប់រឿង ដោយអោយឈ្មោះ អាគរ ជាមេការរបស់ឈ្មោះ [redacted] ប៊ុន យកម៉ាស៊ីនច្រូតស្រូវនោះចេញពីទីតាំងដីហាមឃាត់ ដែលទើបនឹងបានច្រូតស្រូវបានប្រមាណ ៣០% បានស្រូវប្រហែល ២០ ការ៉ុង ម៉ាស៊ីនច្រូតស្រូវដែលបានហាមឃាត់នោះ អាជ្ញាធរស្រុកបានឱ្យឈ្មោះ អាគរ ជាមេការរបស់ឈ្មោះ [redacted] ប៊ុន ប្រគល់ដីជូនរដ្ឋវិញដោយលែងប៉ះពាល់ទៀត។ នៅពេលដែលអាជ្ញាធររួមទាំងសមត្ថកិច្ចចម្រុះ បានធ្វើការដោះស្រាយ សម្របសម្រួលជាមួយឈ្មោះ អាគរ ជាមេការរបស់ឈ្មោះ [redacted] ប៊ុន ប្រគល់ដីជូនរដ្ឋវិញនោះ គឺស្ថិតក្នុងយុទ្ធនាការជុំវិញបឹងទន្លេ ដោយឱ្យប្រជាពលរដ្ឋដែលធ្វើកសិកម្ម និងកាន់កាប់ដីនៅតំបន់ ៣ ខុសច្បាប់ ត្រូវស្ម័គ្រចិត្តប្រគល់ដីជូនរដ្ឋវិញ។ ចម្លើយនេះ គប្បីតុលាការពិចារណា។

៦-លោក [redacted] បាន ជានាយផ្នែកជលផលផ្សារឆ្នាំង បានឆ្លើយបំភ្លឺថា ខ្លួនសូមឆ្លើយបំភ្លឺថា នៅក្នុងរឿងឈូសឆាយដីព្រៃលិចទឹកនេះ ខ្លួនបានចូលរួមត្រួតពិនិត្យកន្លែងកើតហេតុផ្ទាល់ ឃើញថា មានស្លាកស្នាមឈូសឆាយដីព្រៃលិចទឹកនៅពេលយប់ និងព្រោះស្រូវ លើផ្ទៃដីចំនួនប្រហែលជាង ០៤ហិចតា នៅចំណុច ខាងកើតទឹកស្អាតផ្លូវលេខ ៥២ ស្ថិតក្នុងភូមិផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង។ នៅពេលកើតហេតុនោះ ខ្លួនមិនបានឃើញជនល្មើសនោះទេ ព្រោះជនល្មើសបានធ្វើសកម្មភាពច្រើនតែនៅពេលយប់។ បន្ទាប់មក ខ្លួនបានធ្វើការស្រាវជ្រាវរកមុខសញ្ញាជនល្មើស ដែលលួចមកឈូសឆាយដីព្រៃលិចទឹកនោះ ស្រាប់តែក្នុងរយៈពេលដែលកំពុងតែស្រាវជ្រាវនោះ ស្រាប់តែលេចចេញឈ្មោះ [redacted] ប៊ុន បានមកជួបខ្លួន និងជួបលោក [redacted] ន តូ នាយរងអធិការខាងត្បូងបឹងទន្លេសាប បានមកស្នើសុំឱ្យបិទសំណុំរឿង កុំបញ្ជូនទៅតុលាការ នៅពេលនោះ ខ្លួនបានឱ្យឈ្មោះ [redacted] ប៊ុន ទៅជួបជាមួយលោកប្រធានមន្ទីរកសិកម្ម ព្រោះឯកសារខ្លួនបានបញ្ជូនទៅលោកប្រធានមន្ទីរកសិកម្មរួចហើយ។ នៅពេលដែលឈ្មោះ [redacted] ប៊ុន មកជួបខ្លួន និងនាយរងអធិការនោះ ខ្លួនមិន



Scanned with CamScanner

បានធ្វើលិខិតអ្វីនោះទេ គឺជួបនិយាយដោយផ្ទាល់មាត់ ហើយឈ្មោះ [redacted] ប៊ុន បានសុំធ្វើស្រែបន្តទៀត នៅលើដីដែលបានហាមឃាត់នោះ និងមិនបាននិយាយអ្វីប៉ះពាល់ទៅលើឈ្មោះ [redacted] សារិន ហៅ គរ នោះទេ តែជាក់ស្តែង គឺឈ្មោះ [redacted] សារិន ហៅ គរ នេះបានច្រូតស្រូវនៅលើដីខាងលើដែរ។ លុះក្រោយមកខ្លួន និងនាយរងអធិការ បានមកផ្គងយោបល់លោកប្រធានមន្ទីរ តែលោកប្រធានមន្ទីរបានប្រាប់ថា មិនអាចបិទសំណុំរឿងបាននោះទេ ព្រោះរឿងនេះ បានបញ្ជូនមកតុលាការហើយ។ លុះបានរយៈពេលប្រហែល ១ ខែ ទៅ ២ ខែស្រាប់តែឈ្មោះ [redacted] សារិន ហៅ គរ ជាមេការរបស់ឈ្មោះ [redacted] ប៊ុន បានយកម៉ាស៊ីនច្រូតស្រូវមកច្រូតស្រូវ បានប្រមាណ៣០% បានប្រហែល ១០ ការ៉ុង ទើបសមត្ថកិច្ចចម្រុះមាន កងរាជអាវុធហត្ថ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចផលផល បានចុះមកដល់កន្លែងកើតហេតុ ដោយឱ្យឈ្មោះ [redacted] សារិន ហៅ គរ បញ្ឈប់ធ្វើ សកម្មភាពច្រូតស្រូវនៅលើដីតំបន់៣ ដែលរដ្ឋហាមឃាត់។ បន្ទាប់មកខាងជំនាញជលផលបានធ្វើ កំណត់ហេតុស្តីពីការចុះពិនិត្យនិងស្រាវជ្រាវការកាប់បំផ្លាញព្រៃលិចទឹក នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០២១ ដោយមានឈ្មោះ [redacted] សារិន ហៅ គរ បានផ្តិតមេដៃនៅលើកំណត់ហេតុផងដែរ។ នៅពេលសាកសួរនោះ ឈ្មោះ [redacted] សារិន ហៅ គរ មិនបានឆ្លើយដាក់លើ ឈ្មោះ [redacted] ប៊ុន នោះទេ។ លុះបានរយៈពេលប្រហែលកន្លះខែ ស្រាប់តែឈ្មោះ [redacted] ប៊ុន និងប្រពន្ធ បានពឹងខ្ញុំបាទឱ្យជួយជូនមកជួបលោកប្រធានមន្ទីរកសិកម្ម ដើម្បីស្នើសុំធ្វើស្រែបន្តទៀត តែលោក ប្រធានមន្ទីរបានបដិសេធមិនអនុញ្ញាតឱ្យធ្វើស្រែនោះទេ។ ចម្លើយនេះ គប្បីតុលាការពិចារណា។

៧-លោក [redacted] តួ ជានាយរងអធិការខាងត្បូងបឹងទន្លេសាប បានឆ្លើយបំភ្លឺថា នៅក្នុងរឿងឈូសឆាយដីព្រៃលិចទឹកនេះ ខ្លួនបានចូលរួមត្រួតពិនិត្យកន្លែងកើតហេតុផ្ទាល់ ឃើញថា មានស្លាកស្នាមឈូស ឆាយដីព្រៃលិចទឹកនៅពេលយប់ លើផ្ទៃដីចំនួនប្រហែល ០៤ ហិចតា ៧២ អា នៅចំណុចខាងកើតទឹកស្អាត ផ្លូវលេខ ៥២ ស្ថិតនៅក្នុងភូមិ ផ្លូកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់ឆ្នាំង។ នៅពេលកើតហេតុនោះ មិនបានឃើញជនល្មើសនោះទេ ព្រោះជនល្មើសបានធ្វើសកម្មភាពនៅពេលយប់។ បន្ទាប់មក ខ្លួនបានធ្វើការស្រាវជ្រាវរកមុខសញ្ញានៃជនល្មើស ដែលលួចមកឈូសឆាយដីព្រៃលិចទឹកនោះ ស្រាប់តែក្នុងរយៈពេលដែលកំពុងស្រាវជ្រាវនោះ បានប្រហែល ០៣ ថ្ងៃ ស្រាប់តែឈ្មោះ [redacted] ប៊ុន បានតេទូរស័ព្ទទំនាក់ទំនងតាមលេខរបស់គាត់ ០១២ ៧១០ ៦៧៧ មកខ្លួនតាមរយៈលេខទូរស័ព្ទ ០១២ ៣៧ ០០ ១៤ បានស្នើសុំឱ្យខ្លួនជួយអន្តរាគមន៍មកប្រធានមន្ទីរកសិកម្ម ដើម្បីបញ្ឈប់កុំឱ្យបញ្ជូនសំណុំរឿងទៅសាលាដំបូងខេត្តកំពង់ឆ្នាំង។ ពេលនោះ ខ្លួនបានផ្តងយោបល់លោកប្រធានមន្ទីរកសិកម្ម ហើយលោកប្រធានមន្ទីរបានប្រាប់ថា មិនអាចបញ្ឈប់បានទេ ត្រូវតែបញ្ជូនទៅតុលាការ ព្រោះរឿងនេះ ដឹងដល់រដ្ឋមន្ត្រីក្រសួងកសិកម្មហើយ។ នៅពេលដែលឈ្មោះ [redacted] ប៊ុន មកជួបខ្លួននោះមិនបានធ្វើកំណត់ហេតុនោះទេ ព្រោះជួបនិយាយដោយផ្ទាល់មាត់។ លុះបានរយៈពេលប្រហែល ៣ ខែស្រាប់តែឈ្មោះ [redacted] សារិន ហៅ គរ ជាមេការរបស់ឈ្មោះ [redacted] ប៊ុន បានយកម៉ាស៊ីនច្រូតស្រូវមកច្រូតស្រូវបានប្រមាណ ៣០% ទៅ ៤០% តែខ្លួនមិនបានចុះទៅកន្លែងកើតហេតុនោះទេ គឺទទួលដំណឹងពីប្រជាជនរស់នៅទីនោះ។ ក្រោយមក ខ្លួនបានប្រាប់ទៅប្រធានមន្ទីរ ហើយប្រធានមន្ទីរបានទំនាក់ទំនងទៅលោកនាយសង្កាត់ ទើបមានសមត្ថកិច្ចចម្រុះ ,កងរាជអាវុធហត្ថ ,អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចជលផល បានចុះមកដល់កន្លែងកើតហេតុ ដោយឱ្យឈ្មោះ [redacted] សារិន ហៅ គរ បញ្ឈប់ធ្វើសកម្មភាពច្រូតស្រូវនៅលើដីតំបន់ ៣ ដែលរដ្ឋហាមឃាត់។ ឈ្មោះ [redacted] សារិន ហៅ គរ ជាតែកុងឡានដឹកត្រីឱ្យឈ្មោះ [redacted] ប៊ុន រហូតដល់សព្វថ្ងៃនេះឈ្មោះ [redacted] សារិន ហៅ គរ ក៏មិនមានដី និងផ្ទះនៅក្នុងភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូរណ៍ ខេត្ត កំពង់



Scanned with CamScanner

ឆ្នាំង នោះដែរ។ ចម្លើយនេះ គប្បីតុលាការពិចារណា។

៨-សេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការ បានញ្ជាក់ថា៖ ឆ្លងតាមការសួរដេញដោលនៅពេលសវនាការ និងពិនិត្យឯកសារផ្សេងៗក្នុងសំណុំរឿង កាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១ មានការឈូសឆាយដីព្រៃលិចទឹក ដើមឡើយជំនាញជលផលបានធ្វើសេចក្ដីសន្និដ្ឋានតាមរបាយការណ៍សរុបលេខ ០៦ ជផ.កឆ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០២១ តាមការស្រាវជ្រាវរបស់ខ្លួនអ្នកដែលបានប្រព្រឹត្តក្នុងរឿងនេះ មានឈ្មោះ [redacted] ប៊ុន បានឈូសឆាយដីព្រៃលិចអស់ទំហំ ៤ ហិចតា ៧២ អា នៅពេលយប់ ក្រោយមកនៅថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០២១ តាមការបញ្ជាក់របស់ជំនាញថាមានអ្នកទៅទទួល ដែលមានឈ្មោះ [redacted] សារិន ហៅ គរ។ ជាក់ស្ដែងមកដល់ពេលនេះ ឈ្មោះ [redacted] សារិន ហៅ គរ បានឆ្លើយសារភាពថា ខ្លួនជាអ្នកទៅទទួលផល និងបានធ្វើសកម្មភាពកាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១ ការដែលខ្លួនទៅទទួលផលនោះ គឺមិនមានការបញ្ជាពីឈ្មោះ [redacted] ប៊ុន ឬធ្វើការក្នុងនាមឈ្មោះ [redacted] ប៊ុន ដែលជាថៅកែ ឬជាកម្មករដឹកត្រីឲ្យគាត់ទេ អ្វីដែលរបាយការណ៍សរុបរបស់ជលផលបញ្ជូនមកដាក់ថាឈ្មោះ [redacted] ប៊ុន ជាអ្នកប្រព្រឹត្ត មិនជាប់ពាក់ព័ន្ធអ្នកផ្សេងទៀត ដាក់តាមការស្រាវជ្រាវ។ ពេលសួរនាំពីការស្រាវជ្រាវថា ពាក់ព័ន្ធទៅនឹងទូរស័ព្ទថា ឈ្មោះ [redacted] ប៊ុន បានស្នើសុំឲ្យមន្ត្រីជំនាញបិទសំណុំរឿង អ្នកជំនាញបញ្ជាក់ថា ការឲ្យជួយបិទនេះ ដើម្បីអ្នកប្រព្រឹត្ត ឬអ្នកដទៃមិនសំខាន់ទេ ឈ្មោះ [redacted] ប៊ុន ខ្លួនឯងឮថា ជំនាញជលផលបានកសាងសំណុំរឿងថា ខ្លួនជាអ្នកប្រព្រឹត្តបានសុំជួបមន្ត្រីជំនាញទាំងអស់នោះ តាមរយៈទូរស័ព្ទផង អ្នកខ្លះក៏ជួបផ្ទាល់ផង សុំឲ្យមន្ទីរកសិកម្មជួយបិទ កុំឲ្យធ្វើការបញ្ជូន តែទីបំផុតរឿងនេះ ត្រូវបានបញ្ជូនមកតែឈ្មោះ [redacted] ប៊ុន ដោយឡែកឈ្មោះ [redacted] សារិន ហៅ គរ ដែលជាអ្នកទទួលផលនៅក្នុងថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០២១ អត់បានកសាងសំណុំរឿងនោះមកទេ អញ្ចឹងទេមានន័យថា អ្នកដែលបានប្រព្រឹត្ត យើងរកឃើញហើយកាលពីថ្ងៃនោះ ទីបំផុតអត់ធ្វើសំណុំរឿងមក បានធ្វើសំណុំរឿងលេងៗ ផ្សាលៗ សំអាងតាមរយៈទូរស័ព្ទ ហើយសន្និដ្ឋានតែម្ដងថា អ្នកណឹងគឺជាអ្នកប្រព្រឹត្ត អ្នកណឹងជាអ្នកពាក់ព័ន្ធ និងជាអ្នកធ្វើសកម្មភាពកាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១។ បើយើងបូកសរុបលទ្ធផលជុំវិញសវនាការដេញដោល ឃើញថា ឈ្មោះ [redacted] ប៊ុន ហាក់ដូចជាពុំមានសញ្ញាញដែលបញ្ជាក់ថា ជាអ្នកប្រព្រឹត្តក្នុងរឿងនេះទេ ដោយសារតែចម្លើយមន្ត្រីជំនាញថា ឈ្មោះ [redacted] ប៊ុន សុំឲ្យគាត់ជួយបិទសំណុំរឿង និងសុំបង្កបង្កើនផលនៅលើនោះដើម្បីខ្លួនគាត់ផ្ទាល់ ឬដើម្បីអ្នកដទៃ។ ខ្ញុំសូមឲ្យចៅក្រមជំនុំជម្រះពិចារណាលើឈ្មោះ [redacted] ប៊ុន ដែលបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះពីបទ៖ **ឈូសឆាយដីព្រៃលិចទឹក** ប្រព្រឹត្តនៅចំណុចទឹកស្អាត ស្ថិតនៅភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូណ៌ ខេត្ត កំពង់ឆ្នាំង កាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១ និងសូមឲ្យជំនាញយោងតាមមាត្រា១០ និយាយពីអាយុកាលបទល្មើសគិតថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១ ដល់ថ្ងៃសវនាការបានបញ្ជាក់ថា មិនទាន់បានកសាងសំណុំរឿង ទីតាំងអ្នកប្រព្រឹត្តបានសារភាពសូមធ្វើសំណុំរឿងទាំងអស់មកតាមក្រោយ ដោយរៀបរាប់អំពីអង្គហេតុ និងអំពើ ដើម្បីបានជាលទ្ធផលថា អ្នកណាទទួលខុសត្រូវ និងអ្នកណាជាអ្នកប្រព្រឹត្ត បើអញ្ចឹងទេ ទីតាំងណឹងមួយត្រូវបាត់អ្នកទទួលខុសត្រូវ និងអ្នកប្រព្រឹត្តបទល្មើសគ្រាន់តែគិតថាបានប្រគល់ដីនេះ ឲ្យរដ្ឋវិញរួចខ្លួន អញ្ចឹងទេ នឹងមានប្រជាពលរដ្ឋ និងអ្នកប្រព្រឹត្តបទផ្សេងៗទៀតរួចខ្លួនទាំងអស់ គ្រាន់តែប្រគល់ដីឲ្យរដ្ឋវិញនោះ អញ្ចឹងគ្មានអ្នកណាខ្លាច និងគោរពច្បាប់ទេ អញ្ចឹងខ្ញុំសូមណែនាំទៅមន្ត្រីជំនាញ ឲ្យកសាងសំណុំរឿងនេះឡើងវិញ ដែលមានអង្គហេតុ កាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១ និងថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០២១។ ដោយឡែកអង្គហេតុដែលបានចោទប្រកាន់លើឈ្មោះ [redacted] ប៊ុន ដែលមានវត្តមានមក



Scanned with CamScanner

នេះ ខ្ញុំសូមឱ្យចៅក្រមពិនិត្យពិណា ថាតើគាត់បានប្រព្រឹត្ត ឬមិនបានប្រព្រឹត្តបើតាមជំនាញ មិនបានបញ្ជាក់ថាបានប្រព្រឹត្តតែមិនបានសារភាពហើយ ក៏គ្មានភស្តុតាងណាដាក់បន្ទុកថាឈ្មោះ [redacted] ប៊ុន ជាអ្នកធ្វើសកម្មភាពនៅថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១។ សូមឱ្យតុលាការសម្រេចតាមច្បាប់។ សេចក្តីសន្និដ្ឋាន និងការស្នើសុំនេះ គម្បីតុលាការពិចារណា និងសម្រេចតាមច្បាប់។

៩-លោក [redacted] ប៊ុនណ្ណវឌ្ឍន៍ មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុន បានធ្វើសេចក្តីសន្និដ្ឋានការពារថា ខ្ញុំបាទជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុន ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ ៧២១ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តកំពង់ឆ្នាំង ខ្ញុំបាទសូមធ្វើសេចក្តីសន្និដ្ឋានដើម្បីការពារសិទ្ធិឱ្យកូនក្តីខ្ញុំបាទដូចតទៅ៖ ឆ្លងតាមការពិភាក្សាសួរដេញដោល និងសាកសួរនូវសំនួរ បានឱ្យឃើញថា ចម្លើយរបស់ខាងមន្ត្រីជលផលហាក់បីដូចជាមានការច្រពិចច្រពិល ពុំអាចជាភស្តុតាងដាក់បន្ទុកមកលើកូនក្តីខ្លួន ពីបទ: ឈូសឆាយដីព្រៃលិចទឹក បានទេ។ ជាក់ស្តែងកាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១ ពិតជាមានការឈូសឆាយដីព្រៃលិចទឹកពិតមែន ប៉ុន្តែ រកពុំឃើញជនល្មើសណាមួយទៅប្រព្រឹត្តពិតប្រាកដនោះឡើយ។ ហើយខាងជំនាញជលផលដែលបានទទួលដំណឹងថា កូនក្តីខ្លួនបានប្រព្រឹត្តបទល្មើសនេះ គាត់គ្រាន់តែបានទទួលនូវស័ព្ទពីកូនក្តីខ្លួនថា សុំបិទសំណុំរឿង ប៉ុន្តែមិនដឹងសំណុំរឿងខ្លួនឯង ឬអ្នកដទៃនោះទេ គ្រាន់តែទទួលបានការស្នើសុំនេះ គាត់ធ្វើការសន្និដ្ឋានថា អ្នកប្រព្រឹត្តនេះ ជាកូនក្តីរបស់ខ្ញុំបាទឈ្មោះ [redacted] ប៊ុន។ការដែលកូនក្តីខ្ញុំបាទសួរនាំទៅខាងមន្ត្រីជំនាញជលផលនោះ ព្រោះមានការភ័យខ្លាច ដោយសារគាត់មិនមានរឿងអ្វីសោះ បែរជាមានការចោទប្រកាន់ទៅលើរូបគាត់ និងបញ្ជូនសំណុំរឿងទៅតុលាការ ដោយចោទថា គាត់ជាអ្នកឈូសឆាយដីព្រៃលិចទឹកនេះ។ ក្នុងរឿងនេះ សាក្សីឈ្មោះ [redacted] សារិន គាត់បានសារភាពថា គាត់ជាអ្នកប្រព្រឹត្ត អំពើឈូសឆាយដីព្រៃលិចទឹកនេះ កាលថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១ នោះ ហើយគាត់ក៏បានទៅប្រមូលផលនៅលើដីនោះផងដែរ ហើយក៏បានបញ្ជាក់ថា គាត់មិនបានទៅបង្កបង្កើន និងប្រមូលផលស្រូវ យកទៅឱ្យកូនក្តីរបស់ខ្លួនឡើយ។ យ៉ាងទៀតកូនក្តីខ្លួនជាអ្នកមានមុខរបររកស៊ី ទិញលក់ត្រី គាត់តែងតែមានទំនាក់ទំនងខាងមន្ត្រីជលផល តែការទាក់ទងរបស់គាត់ហាក់បីមានការប៉ះទង្គិចជាមួយសមត្ថកិច្ចមួយចំនួន ដូចនេះ អាចថា មកពីគំនុំអ្វីមួយ ក៏អាចថាបានដែរ ពាក់ព័ន្ធចំណុចវិវាទ គឺអត់មានភស្តុតាង ឬឯកសារណា ដែលបញ្ជាក់ថា កូនក្តីខ្លួន បានពាក់ព័ន្ធទៅនឹងការឈូសឆាយដីព្រៃលិចទឹកនោះឡើយទាក់ទងនឹងការបំភ្លឺរបស់មន្ត្រីជលផលនោះគឺ គាត់សំដៅទៅលើតែឈ្មោះ [redacted] សារិន ម្នាក់តែប៉ុណ្ណោះ ពុំពាក់ព័ន្ធជាមួយកូនក្តីរបស់ខ្ញុំបាទឡើយ ហេតុដូច្នេះហើយ ក្នុងរឿងនេះ គឺពុំមានភស្តុតាងដាក់បន្ទុក ធាតុផ្សំបទល្មើសគ្រប់គ្រាន់មកលើកូនក្តីខ្ញុំបាទឈ្មោះ [redacted] ប៊ុន ពីបទ៖ ឈូសឆាយដីព្រៃលិចទឹកនោះទេ។ សំណូមពរ សូមលោកចៅក្រមមេត្តាសម្រេចឱ្យឈ្មោះ [redacted] ប៊ុន រួចផុតពីបទចោទប្រកាន់។ សេចក្តីសន្និដ្ឋាន និងការស្នើសុំនេះ គម្បីតុលាការពិចារណា និងសម្រេចតាមច្បាប់។

១០-ផ្អែកតាមចម្លើយរបស់ជនជាប់ចោទ ,ចម្លើយបំភ្លឺរបស់សាក្សី,ចម្លើយបំភ្លឺរបស់មន្ត្រីនគបាលយុត្តិធម៌ ដែលជានាយផ្នែកជលផលផ្សារឆ្នាំង និងនាយរងអធិការខាងត្បូងបឹងទន្លេសាប , បទចោទប្រកាន់ និងសន្និដ្ឋានរបស់អយ្យការ, របាយការណ៍ដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ និងភស្តុតាងនានានៅក្នុងសំណុំរឿង ឃើញថា គ្មានអំពើ៖ ឈូសឆាយដីព្រៃលិចទឹក ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ប៊ុន ភេទប្រុស អាយុ ៤៩ ឆ្នាំ ជនជាតិខ្មែរ-សញ្ជាតិខ្មែរ ប្រព្រឹត្តនៅចំណុចខាងក្រោយទឹកស្អាត ស្ថិតនៅក្នុងភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូណ៌ ខេត្ត កំពង់ឆ្នាំង កាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១។



Scanned with CamScanner

១១-គ្មានធាតុផ្សំបទល្មើសគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ប៊ុន ភេទប្រុស អាយុ ៤៩ ឆ្នាំ ពីបទ: **ឈូសឆាយដីព្រៃលិចទឹក** ប្រព្រឹត្តនៅចំណុច ក្រោយទឹកស្អាត ស្ថិតនៅក្នុងភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូណ៌ ខេត្ត កំពង់ឆ្នាំង កាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៩៨ ចំណុច ១ នៃច្បាប់ស្តីពីជលផល។

១២-គ្មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ប៊ុន ភេទប្រុស អាយុ ៤៩ ឆ្នាំ ជនជាតិខ្មែរ-សញ្ជាតិខ្មែរ ពីបទ: **ឈូសឆាយដីព្រៃលិចទឹក** ប្រព្រឹត្តនៅចំណុច ក្រោយទឹកស្អាត ស្ថិតនៅក្នុងភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូណ៌ ខេត្ត កំពង់ឆ្នាំង កាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៩៨ ចំណុច ១ នៃច្បាប់ស្តីពីជលផល។ គប្បីតុលាការឱ្យជនជាប់ចោទរួចផុតពីបទចោទខាងលើ។

## ហេតុថ្លែះ វិនិច្ឆ័យសេចក្តី

-ឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុន ភេទប្រុស អាយុ ៤៩ ឆ្នាំ ជនជាតិខ្មែរ-សញ្ជាតិខ្មែរ (មានសាវតារជាតិដូចខាងលើ) រួចផុតបទចោទប្រកាន់ ពីបទ: **ឈូសឆាយដីព្រៃលិចទឹក** ប្រព្រឹត្តនៅចំណុច ក្រោយទឹកស្អាត ស្ថិតនៅក្នុងភូមិ ផ្លុកទ្រូ ឃុំ ផ្លុកទ្រូ ស្រុក បរិបូណ៌ ខេត្ត កំពង់ឆ្នាំង កាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមបញ្ញត្តិមាត្រា ៩៨ ចំណុច ១ នៃច្បាប់ស្តីពីជលផល។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២៤ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ប៊ុន។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃអង្គារ ១១កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
កំពង់ឆ្នាំង,ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២៤

**ក្រឡាបញ្ជី** — ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ** — ហត្ថលេខា និងត្រា [redacted]

---

**"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"**
ថ្ងៃអង្គារ ១១កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
កំពង់ឆ្នាំង,ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០២៤

**បានឃើញ**
**ចៅក្រមជំនុំជម្រះ**
[redacted]

**ក្រឡាបញ្ជី**
[redacted]



Scanned with CamScanner